**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៦៩/០០៧/២០០៩

ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩

**សេចក្តីសម្រេច**

លេខ : ១០៧/០០៣/២០០៩ កបធ.ច

ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ដោយយោងតាមសំណើលេខ ០៦៥/០៩ ស.ន.ក.ជ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៩ របស់គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ១៤ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ

បានធ្វើឡើង ស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន

- យល់ឃើញថា មាត្រា ៤ នៃរដ្ឋធម្មនុញ្ញចែងថា *" បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ "* ។ បាវចនានៃព្រះរាជាណាចក្រកម្ពុជា ជារូបមន្តសរុបមួយតែប៉ុណ្ណោះ បញ្ជាក់អំពីទិសដៅកំណត់សកម្មភាពទាំងឡាយរបស់បុគ្គល រួមមានរូបវន្តបុគ្គល និង នីតិបុគ្គល ដែលរស់នៅ និង មានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ បុគ្គលទាំងនោះត្រូវយកចិត្តទុកដាក់ចំពោះ ជាតិ សាសនា និង ព្រះមហាក្សត្រ ។ ចំពោះការប្រតិបត្តិខាងផ្លូវសាសនា មានកំណត់ក្នុងបទប្បញ្ញត្តិនៃមាត្រាផ្សេងៗទៀតនៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា មាត្រា ៤៣ ចែងអំពីសិទ្ធិខាងជំនឿរបស់ប្រជាពលរដ្ឋខ្មែរ ។

• វាក្យខ័ណ្ឌទី១ ចែងថា *" ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ "* ។ វាក្យខ័ណ្ឌនេះមានន័យថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសេរីភាពបរិបូរណ៍ក្នុងការជឿ ឬ ការប្រតិបត្តិជំនឿ និង សាសនា តាមសតិសម្បជញ្ញៈរបស់ខ្លួន គ្រប់ពេលវេលា និង គ្រប់កាលៈទេសៈ ។

• វាក្យខ័ណ្ឌទី២ ចែងថា *" សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ "* ។ វាក្យខ័ណ្ឌទី២ នេះ មានន័យថា រដ្ឋត្រូវធានាឱ្យសេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនាដំណើរការបានជាធម្មតា **ប៉ុន្តែសេរីភាព និង ការប្រព្រឹត្តនេះ ក៏មានព្រំដែនកំណត់ដែរ** ។ ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃ ព្រមទាំងត្រូវគោរពសិទ្ធិសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ ឬ សាសនារបស់អ្នកដទៃទៀតផង ។ ម្យ៉ាងវិញទៀត ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈជាដាច់ខាត ។

• វាក្យខ័ណ្ឌទី៣ ចែងថា *" ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ "* ។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយវាក្យខ័ណ្ឌទី៣ នៃមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងដូច្នេះហើយ ទើបបទប្បញ្ញត្តិនៃមាត្រាដទៃផ្សេងទៀតនៃរដ្ឋធម្មនុញ្ញ និង អត្ថបទច្បាប់ ព្រមទាំងអត្ថបទក្រោមច្បាប់ កំណត់ស្របតាមស្មារតីខាងលើនេះ

- យល់ឃើញថា ដោយសារ *ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ* ទើប ÷

• នៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋបានផ្តល់ការជួយឧបត្ថម្ភ គាំទ្រ និង លើកតម្កើងវិស័យព្រះពុទ្ធសាសនាឱ្យបានរីកចម្រើន ថ្កុំថ្កើង រុងរឿង ស័ក្តិសមជាសាសនារបស់រដ្ឋ ។ ហេតុនេះ ទើបនៅក្នុងព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រកម្ពុជាគ្រងរាជសម្បត្តិ ក៏មានវត្តមានរបស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ តាមព្រះរាជប្បវេណីដែរ ។ មិនតែប៉ុណ្ណោះ ថ្ងៃបុណ្យធំៗក្នុងព្រះពុទ្ធសាសនា ជាអាទិ៍ថ្ងៃបុណ្យមាឃបូជា វិសាខបូជា ត្រូវបានចាត់ទុកជាថ្ងៃបុណ្យជាតិ

• សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ត្រូវបានឱ្យគង់ជាសមាជិកនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចមានចែងក្នុងមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ម្យ៉ាងទៀតសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះអង្គត្រូវបានគង់ជាអធិបតីក្នុងពិធីធ្វើសច្ចាប្រណិធានធំៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទាំងឡាយនៃរដ្ឋធម្មនុញ្ញ ហើយនៅក្នុងភ្លេងជាតិនគររាជទៀតសោត វគ្គទី៣ ចែងថា " *គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌ សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ ប្រយោជន៍ឱ្យ ដល់ប្រទេសខ្មែរ ជាមហានគរ ។* "

• វាក្យខ័ណ្ឌទី៣ មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា " *រដ្ឋជួយផ្សព្វផ្សាយ និង លើកតម្កើងសាលាបាលី និង ពុទ្ធិកសិក្សា* "

• ហើយប្រជាពលរដ្ឋខ្មែរភាគច្រើនលើសលប់នៅព្រះរាជាណាចក្រកម្ពុជា បានលើក **ទង់ជាតិ ទង់ព្រះពុទ្ធសាសនា** និង **ទង់ព្រះមហាក្សត្រ** នៅទន្ទឹមគ្នា ព្រមទាំងមានសតិសម្បជញ្ញៈជឿជាក់ថា អាណាចក្រ និងពុទ្ធចក្រ ត្រូវដើរទន្ទឹមគ្នា ទើបជាតិបានចុំថ្កើង រុងរឿង ។

## សម្រេច

**មាត្រា ១.** មាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**